**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីស្លាប់ជនជាតិខ្មែរ ចំនួន ០៣នាក់
## ស្ត្រីអាយុ ២៣ឆ្នាំ ស្ត្រីអាយុ ៤៦ឆ្នាំ និង បុរសអាយុ ៦៤ឆ្នាំ ដោយសារជំងឺកូវីដ-១៩

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា យោងតាមរបាយការណ៍ពី៖

១- មន្ទីរពេទ្យមិត្តភាពកម្ពុជាចិនព្រះកុសុមៈ បានឱ្យដឹងថា ស្ត្រីជនជាតិខ្មែរអាយុ ២៣ឆ្នាំ រស់នៅសង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ បានចូលមកព្យាបាល នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ វេលាម៉ោង ២២:៥៥ នាទី ក្នុងស្ថានភាពបាត់បង់ស្មារតី ពេលចូលមកដល់មន្ទីរពេទ្យ ក្រុមគ្រូពេទ្យបានពិនិត្យភ្លាមៗ ហើយបញ្ជាក់ថាអ្នកជំងឺបានស្លាប់បាត់បង់ជីវិតរួចទៅហើយមុនពេលចូលមកដល់មន្ទីរពេទ្យ នៅវេលាម៉ោង២២:៥៥នាទីនា ថ្ងៃដដែល ។

**ការសន្និដ្ឋានរបស់ក្រុមគ្រូពេទ្យ៖** ស្ត្រីជនជាតិខ្មែរអាយុ ២៣ឆ្នាំ ខាងលើនេះ បានស្លាប់បាត់បង់ជីវិតដោយសារជំងឺកូវីដ-១៩ មុនពេលចូលមកដល់មន្ទីរពេទ្យ ( Mourant entrant avec COVID-19 )។

២- មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តត្បូងឃ្មុំ បានឱ្យដឹងថា ស្ត្រីជនជាតិខ្មែរ អាយុ ៤៦ឆ្នាំ រស់នៅស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ មានអាការៈក្តៅខ្លួន ក្អក ហត់ ហើយបានព្យាបាលនៅផ្ទះរយៈពេលមួយសប្តាហ៍ ប៉ុន្តែសភាពជំងឺមិនបានធូរស្រាលទើបក្រុមគ្រួសារបញ្ជូនទៅព្យាបាលបន្តនៅមន្ទីរព្រះបាទនរោត្តមសីហនុត្បូងឃ្មុំ នៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ វេលាម៉ោងណ ១៦:៣០ នាទី ក្នុងស្ថានភាពក្តៅខ្លួន ក្អក ហត់ដង្ហក់ខ្លាំង ពេលមកដល់មន្ទីរពេទ្យ ក្រុមគ្រូពេទ្យបានយកសំណាក ហើយទទួលបានលទ្ធផលបញ្ជាក់ថា មានវិជ្ជមានកូវីដ-១៩ ព្រមទាំងជួយសង្គ្រោះបន្ទាន់តាមលក្ខណៈបច្ចេកទេស រួមទាំងការប្រើប្រាស់ម៉ាស៊ីនជំនួយដង្ហើមផង ក៏នៅតែមិនអាចជួយសង្គ្រោះអ្នកជំងឺបាន គាត់ក៏បានស្លាប់បាត់បង់ជីវិត នៅវេលាម៉ោង ២១:១៨ នាទី នាថ្ងៃខែឆ្នាំដដែល។

**ការសន្និដ្ឋានរបស់ក្រុមគ្រូពេទ្យ៖** ស្ត្រីជនជាតិខ្មែរ អាយុ ៤៦ឆ្នាំ ខាងលើនេះ បានស្លាប់បាត់បង់ជីវិតដោយសារវិបត្តិផ្លូវដង្ហើមស្រួចស្រាវធ្ងន់ធ្ងរ និងរលាកសួតទាំងសងខាង ដោយសារវីរុសកូវីដ-១៩។

៣- មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត បានឱ្យដឹងថា បុរសជនជាតិខ្មែរ អាយុ ៦៤ឆ្នាំ រស់នៅសង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានចូលសម្រាកពេទ្យនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ជាមួយរោគសញ្ញាក្តៅខ្លួន ក្អក ហត់ខ្លាំង រួមទាំងមានប្រវត្តិជំងឺលើសសម្ពាធឈាម និងជំងឺទឹកនោមផ្អែមប្រចាំកាយពេលមកដល់មន្ទីរពេទ្យ ក្រុមគ្រូពេទ្យបានយកសំណាក ហើយទទួលបានលទ្ធផលបញ្ជាក់ថាមានវិជ្ជមានកូវីដ-១៩។ ដោយការវិវត្តិរបស់ជំងឺចេះតែធ្ងន់ធ្ងរឡើងៗ សភាពហត់ដង្ហក់ខ្លាំង ក្រុមគ្រូពេទ្យបានជួយសង្គ្រោះតាមលក្ខណៈបច្ចេកទេសគ្រប់មធ្យោបាយ រួមទាំងការប្រើប្រាស់ម៉ាស៊ីនជំនួយដង្ហើម